## A. សេចក្តីសង្ខេបរួម

### សេចក្តីផ្តើម - ការវិនិយោគរួមលើវិស័យពិការភាព និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (GBV)

ប្រទេសអូស្ត្រាលី មានគោលបំណងប្រើប្រាស់អភិក្រមរួមបញ្ចូលគ្នាតែមួយសម្រាប់អនុវត្តសកម្មភាពរបស់ខ្លួនក្នុងវិស័យពិការភាព និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រនៅកម្ពុជា តាមរយៈកម្មវិធីថ្មីមួយដែលមានរយៈពេល ៥ ឆ្នាំ មានមូលដ្ឋានផ្អែកលើសមិទ្ធផលសម្រេចបាន តាមរយៈការវិនិយោគលើការបញ្ចប់អំពើហិង្សាលើស្ត្រី (EVAW) និងកម្មវិធីលើកកម្ពស់សិទ្ធិជនពិការនៅកម្ពុជា (DRIC) ដែលត្រូវបានអនុវត្តកន្លងមក[1] ។ កម្មវិធីថ្មីនេះនឹងគាំទ្រដល់វឌ្ឍនភាព ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន តាមរយៈកម្មវិធីគាំពារសង្គម និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)។ គេរំពឹងថា ការប្រើប្រាស់អភិក្រមរួមបញ្ចូលគ្នាតែមួយបែបនេះ នឹងអាចបំពេញតម្រូវការផ្តល់សេវាបច្ចុប្បន្ន ធ្វើឲ្យការគ្រប់គ្រងសកម្មភាពអាចធ្វើទៅបានប្រកបដោយប្រសិទ្ធភាព សម្របសម្រួលការងារដែលត្រូវអនុវត្តរួមគ្នារវាងវិស័យទាំងពីរ និងផ្តល់ប្រយោជន៍មកវិញខ្ពស់ពីថវិកាដែលបានចំណាយ។

### បញ្ហាប្រឈមនៃការអភិវឌ្ឍ ដែលបង្កផលលំបាកដល់ការផ្តល់សេវាដល់ស្ត្រីរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ឬជនពិការ

### ក្នុងចំណោមស្ត្រីនៅកម្ពុជាអាយុ ១៥-៦៤ ឆ្នាំ ធ្លាប់មានដៃគូហើយ ៥ នាក់ មានម្នាក់ ធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ

អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រលើស្ត្រី នៅបន្តជាបញ្ហា ក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមស្ត្រីនៅកម្ពុជាអាយុ ១៥-៦៤ ឆ្នាំ ធ្លាប់មានដៃគូហើយ ៥ នាក់ មានម្នាក់បានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ ឬអំពើហិង្សាទាំងពីរប្រភេទ បង្កឡើងដោយដៃគូស្និទស្នាល ក្នុងជីវិតរបស់ពួកគេ និងមាន ៨ ភាគរយធ្លាប់ទទួលរងអំពើហិង្សាប្រភេទនេះ ក្នុងរយៈពេល ១២ ខែ ចុងក្រោយ។ អត្រានៃការទទួលរងអំពើហិង្សាទាំងពីរប្រភេទនេះ មានកម្រិតរឹតតែខ្ពស់ នៅតំបន់ជនបទ។[2] ស្ត្រីជាច្រើននាក់ ពុំបានស្វែងរកជំនួយឡើយ ដោយសារកង្វះសេវាសមស្របផង និងកង្វះការយល់ដឹង ចំណេះដឹង និងសមត្ថភាពរបស់អ្នកផ្តល់សេវា ដែលចាំបាច់ត្រូវមានពង្រឹងបន្ថែម។

[1] កម្មវិធីទាំងពីរនេះត្រូវបានតម្រឹមស្របទៅតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា៖ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-១៨ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពរបស់ប្រទេសកម្ពុជា ២០១៤-១៨។

[2] ការអង្កេតថ្នាក់ជាតិអំពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីនៅកម្ពុជា ធ្វើឡើងដោយក្រសួងកិច្ចការនារី (២០០៥)

## ប្រជាជនកម្ពុជាប្រមាណជា ១០ ភាគរយ មានការលំបាកផ្នែកកាយសម្បទា ហើយតម្រូវការនៃការព្យាបាលមានកម្រិតខ្ពស់

ក្នុងចំណោមប្រជាជនកម្ពុជាអាយុលើសពី ៥ ឆ្នាំ មានប្រមាណជាង ៩,៥ ភាគរយ រាយការណ៍ថាមានពិការភាព ក្នុងទម្រង់ណាមួយ។[3] ២,១ ភាគរយ រាយការណ៍ថា "ជួបការលំបាកខ្លាំង"។[4] ប្រេវ៉ាឡង់នៃភាពខ្សោយ ដែលកើតឡើងចំពោះកុមារអាយុចន្លោះពី ២ ទៅ ៩ ឆ្នាំ គឺ ១៥,៦ ភាគរយ ហើយប្រេវ៉ាឡង់ពិការភាពវិញគឺ ១០,១ ភាគរយ ដូច្នេះ តម្រូវការព្យាបាលមានកម្រិតខ្ពស់ខ្លាំង។[5]

## បញ្ហាប្រឈមផ្នែកសមត្ថភាពផ្តល់សេវា ពាក់ព័ន្ធនឹងពិការភាព និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ

បញ្ហាពាក់ព័ន្ធនឹងការផ្តល់សេវា ដែលត្រូវបានលើកឡើងក្នុង ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ (NAPVAW 2) និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP) រួមមាន៖

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រសួងកិច្ចការនារី ប្រឈមនឹងបញ្ហាកង្វះសមត្ថភាព ក្នុងការបំពេញមុខងារតាក់តែងគោលនយោបាយ និងពិនិត្យតាមដាន ក៏ដូចជាក្នុងការរៀបចំ លើកស្នើ និងការពារតម្រូវការថវិការបស់ខ្លួន។
- ក្រសួងគោលដៅទាំងពីរ (ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ក៏ប្រឈមនឹងការលំបាក ក្នុងការពន្យល់បញ្ចុះបញ្ចូលឲ្យក្រសួងពាក់ព័ន្ធផ្សេងទៀតដាក់បញ្ចូល និងរាយការណ៍ពីសកម្មភាព ដែលក្រសួងទាំងនេះបានទទួលថាជាការទទួលខុសត្រូវរបស់ខ្លួន ក្រោមផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពផងដែរ។
- ដោយឡែកនៅថ្នាក់ក្រោមជាតិ សមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការផ្តល់សេវាក៏នៅមានកម្រិតផងដែរ។ បញ្ហាប្រឈមផ្នែកសមត្ថភាព រួមមាន ការសម្របសម្រួល ដំណើរការថវិកា ការគ្រប់គ្រង និងការចុះផ្តល់អភិបាលបច្ចេកទេស។
- បច្ចុប្បន្ន អង្គការមិនមែនរដ្ឋាភិបាលគឺជាអ្នកផ្តល់សេវាជួរមុខជាច្រើន ជាពិសេស នៅតាមតំបន់ជនបទនៅថ្នាក់ក្រោមជាតិ។
- ការទទួលខុសត្រូវក្នុងការផ្តល់សេវានាពេលអនាគត និងតម្រូវការអភិវឌ្ឍន៍សមត្ថភាព ដែលពាក់ព័ន្ធពុំមានភាពច្បាស់លាស់ឡើយ ដោយសារតែមានការផ្ទេរមុខងារមួយចំនួន ឲ្យស្ថិតក្រោមការទទួលខុស

---

[3] ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (២០១៤)

[4] វិទ្យាស្ថានជាតិស្ថិតិ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល (២០១៥) ការអង្កេតប្រជាសាស្ត្រ និងសុខភាពជាតិ ២០១៤

[5] Evans P et al. (2014) ការសិក្សាអំពីប្រេវ៉ាឡង់នៃភាពខ្សោយ និងពិការភាពរបស់កុមារតូចនៅកម្ពុជា ផ្អែកលើប្រជាជនទូទៅ *Disability, CBR & Inclusive Development*, 25 (2), pp. 5-20.

ត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាផ្នែកមួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ដែលមានក្រសួងមហាផ្ទៃ ជាប្រធាន។

## រាជរដ្ឋាភិបាលកម្ពុជា កំពុងអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគំនិតផ្តួចផ្តើមគាំពារសង្គមរួចទៅហើយ

ការពង្រឹងសេវាបរិយាប័ន្ន ក៏ជាផ្នែកមួយនៃចង្កោមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដោយការផ្តល់សេវា គឺជាកិច្ចការនយោបាយមួយឆ្ពោះទៅរកការបោះឆ្នោតជាតិនៅពាក់កណ្តាលឆ្នាំ ២០១៨។ ដូច្នេះហើយនេះគឺជាពេលសមស្របបំផុត ដែលប្រទេសអូស្ត្រាលីផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងនិរន្តរភាពផ្នែកហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់ដល់ការផ្តល់សេវាបរិយាប័ន្នទាំងនេះ។

- គោលដៅសំខាន់ៗនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ក្រោមការសម្របសម្រួលរបស់ធនាគារពិភពលោក រួមមាន ការបង្កើនភាពជឿជាក់នៃថវិកា ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ការបង្កើនទំនាក់ទំនងរវាងថវិកានិងគោនយោបាយ និងការបង្កើនគណនេយ្យភាពនៃការអនុវត្តការងារ។[6]
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ (SPPF) មានគោលបំណងពង្រឹង និងពង្រីកការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាជម្រុញកំណើនសេដ្ឋកិច្ចជាតិ។ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម មានគោលបំណងធ្វើសុខដុមនីយកម្ម ប្រមូលផ្តុំ និងពង្រឹងគម្រោង ឬកម្មវិធីដែលមានស្រាប់ ដើម្បីបង្កើនស័ក្តិសិទ្ធភាព តម្លាភាព និងសង្គតិភាពនៃប្រព័ន្ធគាំពារសង្គមទាំងមូល។

ប្រទេសអូស្ត្រាលីអាចចូលរួមចំណែកប្រកបដោយអត្ថន័យ ចំពោះការអនុវត្តគោលនយោបាយទាំងនេះរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយប្រើប្រាស់ទំនាក់ទំនង និងបទពិសោធន៍ ដែលខ្លួនមានស្រាប់ក្នុងវិស័យទាំងពីរ។

## លទ្ធផលនៃការអភិវឌ្ឍ ដែលរំពឹងថានឹងសម្រេចបាននៅចុងការវិនិយោគនេះ

**កម្មវិធីសហប្រតិបត្តិការកម្ពុជា-អូស្ត្រាលីដើម្បីការផ្តល់សេវាប្រកបដោយចីរភាព និងសមធម៌** (ហៅកាត់ថា ACCESS) នឹងឆ្លើយតបចំពោះតម្រូវការដែលបានកំណត់។ សមាសភាគសំខាន់ៗនៃកម្មវិធីដែលបានស្នើឡើង រួមមាន៖

- កម្មវិធី ACCESS **នឹងផ្តោតការយកចិត្តទុកដាក់លើការពង្រឹងនិរន្តរភាពហិរញ្ញវត្ថុ ដែលចាំបាច់ សម្រាប់ ផ្តល់សេវាប្រកបដោយគុណភាព ក្នុងវិស័យទាំងពីរ។** កម្មវិធីនេះនឹងតម្រឹមស្របតាមវិធានការកំណែទម្រង់

---

[6] http://www.mef.gov.kh/pfmrp-2nd-launch.html

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា ការកែលំអប្រព័ន្ធថវិកា ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាដើម។[7]កម្មវិធី ACCESS នឹងគាំទ្រដល់ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ដែលជាក្រសួងគោលដៅ) ក្នុងការកែលំអដំណើរការថវិកា ដើម្បីអាចទទួលបានថវិកាច្រើនជាងមុន (ពីសេដ្ឋកិច្ចកម្ពុជាដែលកំពុងមានការរីកចម្រើន) និងដើម្បីអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាព។ កម្មវិធី ACCESS នឹងសហការយ៉ាងជិតស្និទជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើសពីនេះ ក៏នឹងមានការគាំទ្រដល់អភិក្រមថវិកាឆ្លើយតបចំពោះយេនឌ័រផងដែរ។

- **កម្មវិធី ACCESS នឹងខិតខំពង្រឹងទំនាក់ទំនងនៃការផ្តល់សេវារវាងរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពហុភាគី នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមនឹងគាំទ្រដល់ការដឹកនាំការងារផ្តល់សេវារបស់ក្រសួងគោលដៅនៃរាជរដ្ឋាភិបាលកម្ពុជាផង។** យន្តការវិនិយោគដែលមានភាពប្រកួតប្រជែង (CIM)[8] និងការរៀបចំផែនការរួមគ្នាតាមវិស័យ នឹងផ្តល់ឱកាស ដើម្បីសម្រេចគោលដៅខាងលើនេះ។ គេរំពឹងថាលក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ថវិកាគាំទ្រដល់កម្មវិធី ACCESS នឹងមានលក្ខណៈអន្តរវិស័យមួយចំនួន ដូចជា ផែនការវិនិយោគថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាមានបញ្ចូលសកម្មភាពបរិយាប័ន្នសង្គម (ដូចជា សកម្មភាពសម្រាប់ជនពិការ) និងសកម្មភាពគាំទ្រដល់ស្ត្រីរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ជាដើម។ អូស្ត្រាលីនៅបន្តប្តេជ្ញាគាំទ្រដល់ការផ្តល់សេវាក្នុងវិស័យពិការភាពផង និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រផង។
- **កម្មវិធី ACCESS នឹងផ្តល់ការគាំទ្រឲ្យកាន់តែច្រើនបន្ថែមទៀតលើវិស័យពិការភាព ដោយផ្តោតការយកចិត្តទុកដាក់លើការពង្រឹងបរិយាប័ន្នសេដ្ឋកិច្ចសម្រាប់ជនពិការ រួមនឹងពង្រឹងទំនាក់ទំនងរវាងសេវាស្តារលទ្ធភាពពលកម្ម និងបរិយាប័ន្នសង្គម។** ជាពិសេស កម្មវិធី ACCESS នឹងគាំទ្រដល់ការបង្កើតសេវារកការងារឲ្យធ្វើសម្រាប់ជនពិការ ដោយប្រើប្រាស់មេរៀនដែលបានពីគំរូជាតិ និងអន្តរជាតិដែលទទួលបានជោគជ័យកន្លងមក។
- កម្មវិធី ACCESS នឹងអាច**ចូលរួមចំណែកយ៉ាងមានតម្លៃដល់ការសម្រេចគោលដៅនៃក្របខ័ណ្ឌគោល-នយោបាយជាតិគាំពារសង្គម** ដូចជា ពង្រឹងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនពិការ ការរួម

---

[7] http://www.mef.gov.kh/pfmrp.html

[8] យន្តការ CIM នឹងមានបញ្ចូលការផ្តល់ជំនួយដល់អង្គការមិនមែនរដ្ឋាភិបាល តាមរយៈស្ថាប័នដែលជួលឲ្យគ្រប់គ្រងការងារនេះ ការផ្តល់ថវិកាដល់អង្គការពហុភាគី (ដូចជា ទីភ្នាក់ងារសហប្រជាជាតិ) និងការចុះកិច្ចសន្យាជាមួយអ្នកផ្តល់សេវាវិស័យឯកជន។ អ្នកផ្តល់សេវាមកពីវិស័យឯកជន ប្រហែលជាត្រូវឆ្លងកាត់ដំណើរការដេញថ្លៃខ្នាតតូច ដែលក្នុងនោះនឹងមានការកំណត់តម្រូវការសេវាជាក់លាក់ និងមានការព្រមព្រៀងគ្នាពីរបៀបរកសេវាឲ្យបានល្អបំផុតពីវិស័យឯកជន (ឧ. ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ។ល។) ឬតាមរយៈនីតិវិធីលទ្ធកម្មពីប្រភពតែមួយ អាស្រ័យដោយមានការឯកភាពពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី។ ស្ថាប័នដែលជួលឲ្យគ្រប់គ្រងការងារ ត្រូវរៀបរាប់លំអិតពីលក្ខខណ្ឌទាំងនេះ ក្នុងសៀវភៅណែនាំអំពីការអនុវត្ត CIM។

ចំណែកផ្នែកគោលនយោបាយចំពោះកម្មវិធីសន្តិសុខសង្គម (ការលើកកម្ពស់សុខុមាលភាពជនពិការ) និងការរួមចំណែកផ្នែកគោលនយោបាយ ចំពោះការធ្វើសមាហរណកម្មប្រតិបត្តិករសន្តិសុខសង្គមទាំងអស់ ដូចជា មូលនិធិជនពិការ ជាដើម។

› ដោយសារតែមានការប្រើប្រាស់រួមគ្នាសម្រាប់វិស័យអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងវិស័យពិការភាព **កម្មវិធី ACCESS នឹងអាចផ្តោតការយកចិត្តទុកដាក់ពិសេសលើសេវា ដែលគាំទ្រដល់ស្ត្រីពិការ ដែលទទួលរងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងស្ត្រីផ្សេងទៀត ដែលមានជំងឺចិត្តសង្គម ដោយសារអំពើហិង្សា។** ការបញ្ចូលលទ្ធផលចុងកម្មវិធីទីពីរបញ្ចូលគ្នា គឺលំហូរការងារពាក់ព័ន្ធនឹងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងពិការភាព និងជួយឲ្យមានការផ្តល់សេវាពាក់ព័ន្ធប្រកបដោយគុណភាព (សូមមើលខាងក្រោម)។ ពង្រាងគំរូឡូហ្ស៊ីកសម្រាប់កម្មវិធី ACCESS មានបង្ហាញក្នុង**ឧបសម្ព័ន្ធទី ៣**។ តារាងខាងក្រោមបង្ហាញពីគោលបំណង និងលទ្ធផលដែលត្រូវបានស្នើឡើង និងការពិពណ៌នាអំពីលទ្ធផលចុងកម្មវិធី (EOPOs) និងលទ្ធផលរយៈពេលមធ្យម (IOs) របស់កម្មវិធី ACCESS។

| **គោលបំណងរបស់កម្មវិធី ACCESS៖ បង្កើននិរន្តរភាពសេវាបរិយាប័ន្នប្រកបដោយគុណភាព** | |
|---|---|
| **លទ្ធផលចុងកម្មវិធីទី ១៖ កែលំអដំណើរការថវិកា សម្រាប់គាំទ្រដល់ការផ្តល់សេវាដល់ជនពិការ និងស្ត្រីដែលរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ** | |
| **សមាសភាគការងារ** | **លទ្ធផលរយៈពេលមធ្យម** |
| **១.១ ផ្តោតលើរាជរដ្ឋាភិបាលកម្ពុជា** | ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ នឹងអាចរៀបចំ លើកស្នើ និងការពារតម្រូវការថវិកាសម្រាប់អនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព កាន់តែមានប្រសិទ្ធភាព។ |
| | ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ នឹងធ្វើការតស៊ូមតិកាន់តែប្រសិទ្ធភាព ដើម្បីឲ្យក្រសួងពាក់ព័ន្ធអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ |
| **១.២ ផ្តោតលើអង្គការមិនមែនរដ្ឋាភិបាល** | អង្គការមិនមែនរដ្ឋាភិបាល កាន់តែមានប្រភពថវិកាចម្រុះ និងមាននិរន្តរភាពសម្រាប់ផ្តល់សេវា។ |
| **លទ្ធផលចុងកម្មវិធីទី ២៖ បង្កើនភាពងាយស្រួលក្នុងការទទួលបានសេវាប្រកបដោយគុណភាព សម្រាប់ជនពិការ និងស្ត្រីដែលរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ** | |

| | |
|---|---|
| **២.១ អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ** | បង្កើនការអនុម័ត និងការអនុវត្តបទដ្ឋានសេវាដែលមានស្រាប់ សម្រាប់ស្ត្រីរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ |
| | ក្រសួងកិច្ចការនារី ផ្តល់ការគាំទ្រដល់បណ្តាញបញ្ជូន និងសម្របសម្រួល នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព។ |
| **២.២ ពិការភាព** | សេវាស្តារលទ្ធភាពពលកម្ម និងសេវាស្វែងរកការងារឲ្យធ្វើ គាំទ្រដល់ការបង្កើនបរិយាប័ន្នសេដ្ឋកិច្ចរបស់ជនពិការ។ |
| | មូលនិធិជនពិការ កាន់តែមានភាពម្ចាស់ការ ក្នុងការគ្រប់គ្រងសេវាស្តារលទ្ធភាពពលកម្ម។ |
| | សេវាស្វែងរកការងារឲ្យធ្វើ ត្រូវបានបង្កើតឡើងសម្រាប់ជនពិការ។ |
| **៣. អន្តរវិស័យ** | ផែនការវិនិយោគថ្នាក់ក្រោមជាតិលើកកម្ពស់បរិយាប័ន្ន និងការឆ្លើយតបចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។ |

**លទ្ធផលចុងកម្មវិធីទី ១៖ កែលំអដំណើរការថវិកា សម្រាប់គាំទ្រដល់ការផ្តល់សេវាដល់មូលនិធិជនពិការ និងស្ត្រីដែលរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ**

លទ្ធផលនេះមានលំហូរការងារចំនួនពីរ ដែលផ្តោតការយកចិត្តទុកដាក់លើការបង្កើនការផ្តល់ថវិកាប្រកបដោយចីរភាពដល់ជនពិការ ឬអ្នកដែលរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។

*១.១ សមាសភាគការងារដែលផ្តោតលើរាជរដ្ឋាភិបាលកម្ពុជា*

សមាសភាគការងារនេះនឹងផ្តោតសំខាន់លើ**ការកសាងសមត្ថភាពក្នុងក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការរៀបចំ លើកស្នើ និងការពារថវិកា** ដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ លទ្ធផលរយៈពេលមធ្យមចំនួនពីរ ត្រូវបានកំណត់ដូចខាងក្រោម។

**លទ្ធផលរយៈពេលមធ្យម៖ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ នឹងអាចរៀបចំ លើកស្នើ និងការពារតម្រូវការថវិកាសម្រាប់អនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព កាន់តែមាន ប្រសិទ្ធភាព។**

លទ្ធផលរយៈពេលមធ្យមនេះផ្តោតលើការពង្រឹងសមត្ថភាពរបស់ក្រសួងគោលដៅទាំងពីរ ក្នុងការអនុវត្តវិធានការកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ នឹងមានការកសាងកិច្ចសហប្រតិបត្តិការបច្ចេកទេសកាន់តែជិតស្និទ្ធរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងគោលដៅ តាមរយៈ

ការគាំទ្រជំនួយបច្ចេកទេស (TA) ដូចជា ការរៀបចំ និងវិភាគលើកស្តុតាងដែលអាចជឿទុកចិត្តបាន សម្រាប់ប្រើជាមូលដ្ឋានក្នុងការរៀបចំថវិកាឆ្លើយតបចំពោះយេនឌ័រ ដែលមានការប៉ាន់ប្រមាណក្នុងលក្ខណៈប្រាកដនិយម។ ការប្រើប្រាស់ការរៀបចំស្ថាប័នដែលមានស្រាប់ ដូចជា មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកំពុងប្រចាំការក្នុងក្រសួងគោលដៅទាំងពីរ គឺជាការងារដែលសំខាន់ និងចាំបាច់។ ការធ្វើបែបនេះនឹងត្រួសត្រាយផ្លូវឲ្យមានការកែលំអដំណើរការថវិកា និងនាំឲ្យមានការបង្កើនថវិកាប្រកបដោយចីរភាព។

**លទ្ធផលរយៈពេលមធ្យម៖ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ នឹងធ្វើការតស៊ូមតិកាន់តែប្រសិទ្ធភាព ដើម្បីឲ្យក្រសួងពាក់ព័ន្ធអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។**

ផ្សារភ្ជាប់ជាមួយនឹងលទ្ធផលរយៈពេលមធ្យមមុននេះ តាមរយៈការតម្រឹមឲ្យស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា និងតាមរយៈការវិភាគលើស្ថានភាពសេដ្ឋកិច្ចនយោបាយជាប្រចាំ កម្មវិធី ACCESS នឹងធ្វើការងារជាមួយក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ **ដើម្បីបង្កើតភស្តុតាង និងធ្វើការវិភាគ សម្រាប់ជួយដល់ក្រសួងពាក់ព័ន្ធផ្សេងទៀត ដែលមិនមែនជាក្រសួងគោលដៅ និងមានការទទួលខុសត្រូវក្រោមផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ដើម្បីអាចអនុវត្តតាមការទទួលខុសត្រូវរបស់ខ្លួន ដូចមានចែងក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។** ទំនងជានឹងមានការចូលរួមសហការដំបូងៗ ជាមួយក្រសួងសុខាភិបាល។ អភិក្រមបែបនេះនឹងកសាងសមត្ថភាពផ្តល់ប្រឹក្សាបច្ចេកទេសពាក់ព័ន្ធនឹងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព របស់ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ នៅពេលដែលស្ថាប័នទាំងនេះផ្តល់ការគាំទ្រដល់ក្រសួងពាក់ព័ន្ធ ដែលជួបការលំបាក ក្នុងការរៀបចំផែនការ និង អនុវត្តការទទួលខុសត្រូវរបស់ខ្លួន។ ការកសាងទំនាក់ទំនង និងការបង្កើត និងការវិភាគទិន្នន័យ គឺជាសមាសភាគសំខាន់ៗ នៃអភិក្រមនេះ។

ការសហការជាមួយក្រសួងមហាផ្ទៃ ពាក់ព័ន្ធនឹងវិសាលភាពនៃសកម្មភាព ដែលអនុវត្តដោយគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ (គ.ព.ស.ក) នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក និងគណៈកម្មាធិការកិច្ចការនារី និងកុមារ (គ.ក.ន.ក) នៅថ្នាក់ឃុំ ក៏ស្ថិតក្នុងគម្រោងដែលត្រូវធ្វើផងដែរ។ អ្នកពាក់ព័ន្ធភាគច្រើន (ដូចជា នគរបាល អ្នកផ្តល់សេវាសុខភាព ជនបង្គោលស្ត្រី និងកុមារ មន្ត្រីសង្គមកិច្ច និងមន្ត្រីកិច្ចការនារី) នៅថ្នាក់ក្រោមជាតិ គឺជាសមាជិករបស់ គ.ព.ស.ក ឬ គ.ក.ន.ក។ យន្តការទាំងនេះមានភារកិច្ចផ្តល់សេវាដល់ជនរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។ ក្នុងការអនុវត្តជាក់ស្តែង ថវិកាសម្រាប់សកម្មភាពរបស់ គ.ព.ស.ក ត្រូវបានផ្តល់តាមរយៈក្រសួងមហាផ្ទៃ។ ប៉ុន្តែ បច្ចុប្បន្ននេះ ថវិកាភាគច្រើនមិនផ្តោតលើការផ្តល់សេវា

ដល់ស្ត្រី និងកុមារ ដែលរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រឡើយ ប៉ុន្តែប្រើតែសម្រាប់ការបង្កើនការយល់ដឹងតែប៉ុណ្ណោះ។

ការពង្រឹងក្រសួងគោលដៅទាំងពីរឲ្យក្លាយជាជាប្រភពចំណេះដឹង ព័ត៌មាន និងការគាំទ្របច្ចេកទេសដល់ក្រសួងពាក់ព័ន្ធ ក្នុងការអនុវត្តការទទួលខុសត្រូវដែលត្រូវបានកំណត់ក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព នឹងបង្កើតនូវទំនាក់ទំនងជាវិជ្ជមាន។ គេរំពឹងថា សកម្មភាពនេះនឹងរួមចំណែកឆ្លើយតបចំពោះបញ្ហាកកស្ទះ ដែលក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំពុងជួបប្រទះ ក្នុងការលើកទឹកចិត្តឲ្យក្រសួងពាក់ព័ន្ធអនុវត្តផែនការសកម្មភាពរបស់ខ្លួន។ កិច្ចប្រជុំសម្រាប់សមាសភាគការងារនេះ នឹងផ្តល់នូវឱកាស សម្រាប់ធ្វើការពិគ្រោះយោបល់គោលនយោបាយ ដូចជា ការដាក់បញ្ចូលពិការភាព និងគោលនយោបាយស្តីពីសមភាពយេនឌ័រ ជាដើម និងរៀបចំ យុទ្ធសាស្ត្របន្ថែម ដែលបន្ទាប់មក អាចយកទៅបម្លែងជាសំណើគម្រោងបាន។

### ១.២ សមាសភាគការងារដែលផ្តោតលើអង្គការមិនមែនរដ្ឋាភិបាល

ជាមួយនឹងការទទួលស្គាល់ថា និរន្តរភាពផ្នែកហិរញ្ញវត្ថុ គឺជាបញ្ហាផ្ទៃក្នុងរបស់អង្គការមិនមែនរដ្ឋាភិ-បាលនីមួយៗ សមាសភាគការងារនេះនឹងជម្រុញឲ្យមានការ**បង្កើតយុទ្ធសាស្ត្រធ្វើពិពិធកម្មការផ្តល់មូលនិធិមួយដែលអង្គការមិនមែនរដ្ឋាភិបាល ជាពិសេស អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចដាក់ពាក្យសុំមូលនិធិបាន។** យុទ្ធសាស្ត្រនេះនឹងបញ្ចូលលទ្ធភាពទទួលបានមូលនិធិពីវិស័យឯកជន ដូចជា តាមរយៈការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន និងសកម្មភាពសហគ្រិនភាពសង្គម ក្នុងប្រទេសកម្ពុជា ជាដើម។ អាចមានឪការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡា ដែលឧបត្ថម្ភដោយក្រុមហ៊ុនឯកជន ឬការរៀបចំយុទ្ធនាការផ្សព្វផ្សាយ/ដាក់រូបឡូហ្គោដែលបង្ហាញពីការគាំទ្ររបស់ក្រុមហ៊ុន ចំពោះគំនិតផ្តួចផ្តើម ដែលផ្តោតលើជនពិការ និងស្ត្រីរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។

### លទ្ធផលរយៈពេលមធ្យម៖ អង្គការមិនមែនរដ្ឋាភិបាល កាន់តែមានប្រភពថវិកាចម្រុះ និងមាននិរន្តរភាព សម្រាប់ផ្តល់សេវា។

**លទ្ធផលរយៈពេលមធ្យមនឹងនឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងធ្វើពិពិធកម្មប្រភពមូលនិធិ** ជាពិសេស សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលអូស្ត្រាលីបាន និងកំពុងធ្វើការងារជាមួយជាច្រើនឆ្នាំមកហើយ ហើយដែលនៅបន្តបំពេញតួនាទីសំខាន់ ក្នុងការផ្តល់សេវា ក្នុងវិស័យទាំងពីរ។ លទ្ធផលរយៈពេលមធ្យមនេះព្យាយាមផ្តោតការយកចិត្តទុកដាក់លើការបន្តផ្តល់សេវា ហើយក្នុងពេលជាមួយគ្នា ស្វែងរកប្រភពថវិកាចម្រុះក្នុងប្រទេស និងកសាងនិរន្តរភាពនៃប្រភពថវិកាទាំងនោះ សម្រាប់គាំទ្រដល់សេវា ដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។

**លទ្ធផលចុងកម្មវិធីទី ២៖ បង្កើនភាពងាយស្រួលក្នុងការទទួលបានសេវាប្រកបដោយគុណភាព សម្រាប់ជនពិការ និងស្ត្រីដែលរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ**

ក្រោមលទ្ធផលចុងកម្មវិធីនេះ នឹងមានសមាសភាគសកម្មភាពចំនួនពីរ ដែលផ្តោតលើក្រុមគោលដៅទាំងពីរ (ជនពិការ និងស្ត្រីរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ)។ សកម្មភាពក្នុងសមាសភាគការងារ ដែលស្ថិតក្រោមលទ្ធផលចុងកម្មវិធីនេះ អាចពង្រីកបន្ថែម ដើម្បីបញ្ចូលសេវា និងក្រុមគោលដៅផ្សេងទៀត នៅពេលដែលមានថវិកា។ **ដំបូង នឹងមានការផ្តោតជាសំខាន់លើសមាសភាគវិស័យសុខាភិបាល នៃសមាសភាគការងារទាំងពីរនេះ។** នេះឆ្លុះបញ្ចាំងការតម្រឹមការងារបច្ចេកទេសនៃសមាសភាគការងារទាំងពីរនេះឲ្យស្របគ្នា ប្រើប្រាស់សមិទ្ធផលសម្រេចបានក្នុងកម្មវិធី EVAW និង DRIC កន្លងមក និងបង្កើនកម្លាំងផ្ទួបជាមួយនឹងការវិនិយោគក្នុងវិស័យសុខាភិបាលរបស់ DFAT ដូចជា គម្រោងបង្កើនសមធម៌ និងគុណភាពនៃសេវា សុខាភិបាលនៅកម្ពុជា (H-EQIP) ជាដើម។ ការសហការបច្ចេកទេស ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងថ្នាក់ក្រោមជាតិ នឹងធ្វើឡើងតាមពីរបែប៖ តាមរយៈយន្តការរបស់រាជរដ្ឋាភិបាលកម្ពុជា (ដែលត្រូវបានពង្រឹង) (ដូចជា តំណាងនៅថ្នាក់ជាតិរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានសមត្ថភាពបំពេញការងារជាមួយសមភាគីរបស់ខ្លួន នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក) និងតាមរយៈអ្នកផ្តល់សេវាដែលធ្វើការងារជាមួយនឹងស្ថាប័នរាជរដ្ឋាភិបាលកម្ពុជានៅថ្នាក់ក្រោមជាតិ។ ក្នុងសំណើសកម្មភាព នឹងមានការបញ្ជាក់ពីទម្រង់ការនានា ដែលត្រូវបានកែសម្រួលឲ្យស្របតាមសកម្មភាពពាក់ព័ន្ធ។

## ២.១ សមាសភាគការងារទាក់ទិននឹងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ

ខណៈពេលដែលសកម្មភាពក្នុងសមាសភាគនេះផ្តោតលើការផ្តល់សេវា អភិក្រមជារួម និងលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអង្គការទទួលថវិកា នឹង**ផ្តោតការយកចិត្តទុកដាក់លើការប្រាបាច់គោលការណ៍ទប់ស្កាត់នានាបញ្ចូលគ្នា។** ចំណុចនេះផ្តោតលើការទប់ស្កាត់បឋម ពាក់ព័ន្ធនឹងតួនាទីរបស់អ្នកផ្តល់សេវាក្នុងការផ្លាស់ប្តូរបទដ្ឋានសង្គមជុំវិញការទទួលយក និងការពឹងផ្អែកលើអំពើហិង្សាផង និងការទប់ស្កាត់កម្រិតទីពីរ ដែលពាក់ព័ន្ធនឹងតួនាទីរបស់អ្នកផ្តល់សេវា ក្នុងការកាត់បន្ថយមិនឲ្យមានករណីអំពើហិង្សាបន្ថែមទៀតផង។ គេរំពឹងថា អង្គការដែលទទួលបានជំនួយ និងអ្នកផ្តល់សេវាកសាងសមត្ថភាព ឬទីភ្នាក់ងារគាំទ្រនានា នឹងដាក់បញ្ចូល យុទ្ធសាស្ត្រលើកកម្ពស់តួនាទីរបស់អ្នកផ្តល់សេវា និងអ្នកដឹកនាំសហគមន៍ ក្នុងការជម្រុញឲ្យមានបទដ្ឋានសង្គមជាវិជ្ជមាន។ នឹងមានការគាំទ្របច្ចេកទេសបន្ថែម និងសកម្មភាពរៀនសូត្រនិងអភិវឌ្ឍន៍ជាក់លាក់សម្រាប់ចំណុចនេះ។ ចាំបាច់ត្រូវមានភាពបត់បែនមួយចំនួន ក្នុងការផ្តល់ការគាំទ្រដល់សកម្មភាពទប់ស្កាត់បឋមឲ្យចំគោលដៅ ដូចដែលត្រូវបានកំណត់ជាអាទិភាព និងឯកភាពរួមគ្នាដោយក្រសួងកិច្ចការនារី ដូចជា ការលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថ ដើម្បីទប់ស្កាត់អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រលើស្ត្រី តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ក៏ដូចជាការជម្រុញឲ្យមានការចូលរួមពីយុវជន ជាដើម។

**លទ្ធផលរយៈពេលមធ្យម៖ បង្កើនការអនុម័ត និងការអនុវត្តបទដ្ឋានសេវា សម្រាប់ស្ត្រីរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ**

លទ្ធផលនេះផ្តល់អាទិភាពដល់ការផ្តល់សេវាក្នុងវិស័យចំនួនពីរ៖

**វិស័យសុខាភិបាល៖ ការផ្តល់ប្រឹក្សា និងការគាំទ្រចិត្តសង្គម** ដូចដែលត្រូវបានដាក់ចេញក្នុងបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាកម្រិតមូលដ្ឋានដល់ស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (រៀបចំដោយក្រសួងសុខាភិបាល និងក្រសួងកិច្ចការនារី ឆ្នាំ ២០១៦) និងតួនាទីនៃសេវាសុខភាព ដូចដែលត្រូវបានលើកឡើងក្នុងគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការគ្រប់គ្រងករណីអំពើហិង្សាលើស្ត្រី និងសៀវភៅណែនាំគ្លីនិកអំពីការថែទាំសុខភាពសម្រាប់ស្ត្រីដែលទទួលរងអំពើហិង្សាពីដៃគូស្និទស្នាល ឬអំពើហិង្សាផ្លូវភេទ (រៀបចំដោយក្រសួងសុខាភិបាល ឆ្នាំ ២០១៦)។

**វិស័យយុត្តិធម៌៖** ការអនុវត្តគោលការណ៍ណែនាំស្តីពីការផ្សះផ្សានាពេលខាងមុខនេះ (រំពឹងថាក្នុងឆ្នាំ ២០១៧) នឹងមានការផ្តល់ជំនួយផ្នែកច្បាប់ និងអាចមានការពង្រឹងតួនាទីរបស់ភ្នាក់ងារនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី។ ពុំមានការលើកស្នើឲ្យមានការសហការជាមួយវិស័យយុត្តិធម៌ផ្លូវការ ក្រៅតែចំណុចនេះទេ។ កម្មវិធីនេះក៏អាចរិះរកឱកាសគាំទ្រដល់ការពង្រឹងការឆ្លើយតបរបស់វិស័យសុខាភិបាល-ច្បាប់ និងការភ្ជាប់ទំនាក់ទំនងរវាងសកម្មភាពក្នុងវិស័យសុខាភិបាល ជាមួយនឹងសកម្មភាពក្នុងវិស័យយុត្តិធម៌ផងដែរ។

អាចមានការផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងផ្តល់សេវា និងសម្របសម្រួលផ្សេងទៀតដែរ ទៅតាមការផ្តល់ដំបូន្មានរបស់ក្រសួងកិច្ចការនារី និងដោយមានការពិចារណាលើតម្រូវការនៃការបញ្ជូន (សូមមើលលទ្ធផលខាងក្រោម)។ ចំណុចនេះមានគោលបំណងផ្តល់ការគាំទ្រដល់វឌ្ឍនភាព ក្នុងការឈានទៅសម្រេចសំណុំសេវាជាសារវ័ន្ត សម្រាប់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយសារអំពើហិង្សា ដែលត្រូវបានរៀបចំឡើងដោយ UN Women, UNFPA, UNDP, WHO និង UNODC ដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី និងអេស្ប៉ាញ។[9]

**លទ្ធផលរយៈពេលមធ្យម៖ ក្រសួងកិច្ចការនារី ផ្តល់ការគាំទ្រដល់បណ្តាញបញ្ជូន និងសម្របសម្រួល នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព។**

សកម្មភាព ក្រោមលទ្ធផលរយៈពេលមធ្យមនេះ **នឹងផ្តោតលើតួនាទីរបស់ក្រសួងកិច្ចការនារី ក្នុងការកសាងសមត្ថភាពបណ្តាញទំនាក់ទំនង និងភាពអនុលោមទៅតាមគោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (រៀបចំដោយក្រសួងកិច្ចការនារី ឆ្នាំ ២០១៦)។** ការងារនេះ នឹងប្រើប្រាស់អភិក្រមសហគមន៍អ្នកអនុវត្តការងាររបស់គម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់

[9] UN Women et al (2015) *Essential Services Package for Women and Girls Subject to Violence Core Elements and Quality Guidelines.* UN Women: New York

ស្ត្រីដំណាក់កាលទី ២ (ATJW2) ដែលបច្ចុប្បន្ន ត្រូវបានបញ្ចូលជាអនុក្រុមមួយរបស់ គ.ព.ស.ក ហៅថា ក្រុមការងារផ្តោតលើអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។ គោលបំណង **គឺដើម្បីបង្កើតនូវគំរូមជ្ឈមណ្ឌលផ្តល់សេវាគ្រប់បែបយ៉ាងនៅកន្លែងតែមួយ ដែលក្រសួងកិច្ចការនារីតស៊ូមតិជម្រុញឲ្យមាន**។ ការពង្រីកអ្វីក៏ដោយ ត្រូវធ្វើឡើងផ្អែកទៅតាមការរៀបចំផែនទីបង្ហាញពីសេវាដែលមាន និងតម្រូវការ ដែលត្រូវធ្វើឡើងឲ្យបានហ្មត់ ចត់។ មន្ទីរកិច្ចការនារី គ.ព.ស.ក និង គ.ក.ន.ក គឺជាតួអង្គពាក់ព័ន្ធសំខាន់ៗ។ កម្មវិធី ACCESS នឹងរិះរកឱកាសភ្ជាប់ទំនាក់ទំនងជាមួយនឹងការងារគំនិតផ្តួចផ្តើមនគរបាលសហគមន៍ ដែលទទួលបានថវិកាគាំទ្រពី DFAT កម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រីនិងកុមារីរងគ្រោះដោយអំពីហិង្សា និងជាមួយភ្នាក់ងារ និងមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី។

*២.២ សមាសភាគពិការភាព*

**លទ្ធផលរយៈពេលមធ្យម៖ សេវាស្តារលទ្ធភាពពលកម្ម និងសេវាស្វែងរកការងារឲ្យធ្វើ គាំទ្រដល់ការបង្កើនបរិយាប័ន្នសេដ្ឋកិច្ចរបស់ជនពិការ។**

កម្មវិធី ACCESS នឹងចាប់ផ្តើម**ចូលរួមធ្វើការងារពាក់ព័ន្ធនឹងបរិយាប័ន្នសេដ្ឋកិច្ច** ផ្តោតលើជនពិការ ហើយប្រសិនបើមានការបង្កើនថវិកា កម្មវិធី ACCESS នឹងពិនិត្យលើលទ្ធភាពពង្រីកសកម្មភាពផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ឬក្រុមដែលមិនមានឱកាសផ្សេងទៀតផងដែរ។ **ចំណុចផ្តោតដំបូង គឺលើបរិយាប័ន្នសង្គម តាមរយៈសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ដូចជា ការផ្តល់អវយវៈសិប្បនិម្មិត និងឧបករណ៍ជំនួយផ្សេងទៀត និងលើការផ្តល់ការងារក្នុង វិស័យរៀបរយ តាមរយៈសេវាស្វែងរកការងារឲ្យធ្វើ និងការបង្កើនការយល់ដឹងអំពីកន្លែងធ្វើការដែលបញ្ចូលជនពិការឲ្យធ្វើការ ក៏ដូចជាការពង្រឹងការត្រៀមខ្លួនធ្វើការងាររបស់ជនពិការ។** កម្មវិធី ACCESS ចាត់ទុកការលើកកម្ពស់ សហគ្រិនភាព ឬការចូលរួមរបស់ជនពិការ ថាជាការគាំទ្រដល់សហគ្រាសដែលមានចីរភាព និងមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ។ កម្មវិធី ACCESS នឹងមិនគាំទ្រដល់ការបណ្តាក់ទុនរួមគ្នាដែលរៀបចំមិនបានល្អ ផ្អែកលើជំនាញកម្រិតទាប ដោយពុំមានការបង្កើតទំនាក់ទំនងទីផ្សារឲ្យបានច្បាស់លាស់នោះទេ។ សំណើផ្តោតលើបញ្ហាដែលជនពិការមកពីក្រុមផ្សេងៗគ្នាជួបប្រទះដូចៗគ្នា (ដូចជា កុមារ មនុស្សចាស់ ស្ត្រី អ្នកស្រលាញ់ភេទដូចគ្នា) អាចធ្វើឡើងតាមរយៈយន្តការ CIM។

**លទ្ធផលរយៈពេលមធ្យម៖ មូលនិធិជនពិការកាន់តែមានភាពម្ចាស់ការ ក្នុងការគ្រប់គ្រងសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា**

សកម្មភាពក្រោមលទ្ធផលរយៈពេលមធ្យមនេះ **នឹងកសាងសមត្ថភាពគ្រប់គ្រង ដើម្បីឲ្យមានការផ្តល់សេវាប្រកបដោយគុណភាព និងនិរន្តរភាព ក្រោយការផ្ទេរសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ដែលបច្ចុប្បន្នកំពុងដំណើរការ ដោយមានការគាំទ្រពីអង្គការអន្តរជាតិជាច្រើន ទៅឲ្យមូលនិធិជនពិការ តាមផែនការដែលបាន**

**គ្រោងទុករួច។** កម្មវិធី ACCESS ចាត់ទុកសេវាសេវាស្តារលទ្ធភាពពលកម្មជាអាទិភាព ដោយហេតុថាសេវាទាំងនេះផ្តល់លទ្ធភាពឲ្យមានបរិយាប័ន្នសង្គម និងសេដ្ឋកិច្ច ក៏ដូចជាផ្តល់ការគាំទ្រចិត្តសង្គម ដល់ក្រុមគោលដៅ និងគ្រួសាររបស់ពួកគេ។ លទ្ធផលនេះនឹងពិចារណាលើបណ្តាញដែលមានស្រាប់នៃមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាទាំង ១១ មជ្ឈមណ្ឌលព្យាបាលរបួសខួរឆ្អឹងខ្នង រោងចក្រផលិតរណប និងរោងជាងជួសជុលអវយវៈសិប្បនិម្មិត និងរណបទាំង ៣។

**លទ្ធផលរយៈពេលមធ្យម៖ សេវាស្វែងរកការងារឲ្យធ្វើ ត្រូវបានបង្កើតឡើងសម្រាប់ជនពិការ**

កម្មវិធី ACCESS នឹងប្រើប្រាស់អភិក្រមចម្រុះ ក្នុងផ្នែកដែលនឹងត្រូវយកមកពិចារណានេះ។ ដំបូង នឹងមានការផ្តោតលើការបង្កើតសេវាស្វែងរកការងារឲ្យធ្វើ ដោយផ្សារភ្ជាប់ជនពិការ ជាមួយនឹងឱកាសការងារ និងមុខរបរនានា។ សកម្មភាពទាំងនេះនឹងបញ្ចូលការលុបបំបាត់ការមាក់ងាយ និងការរើសអើងលើជនពិការ ដែលកំពុងស្វែងរកការងារ ដោយមានការផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការធានាយ៉ាងណាឲ្យស្ត្រីពិការមានសមត្ថភាពស្មើគ្នា ក្នុងការប្រើប្រាស់សេវារកការងារធ្វើនេះ។

**៣. សមាសភាគអន្តរវិស័យ**

**លទ្ធផលរយៈពេលមធ្យម៖ ផែនការវិនិយោគថ្នាក់ក្រោមជាតិលើកកម្ពស់បរិយាប័ន្ន និងការឆ្លើយតបចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ**

កម្មវិធី ACCESS នឹងវិនិយោគលើការងាររបស់អង្គការជនពិការ អង្គការមិនមែនរដ្ឋាភិបាល ទីភ្នាក់ងារអន្តរជាតិ និងដៃគូផ្សេងទៀត ក្នុងវិស័យទាំងពីរ ដែលកំពុងចូលរួមរៀបចំ និងមានឥទ្ធិពលលើផែនការវិនិយោគឃុំ និងផ្សារភ្ជាប់ទំនាក់ទំនង ជាមួយនឹងគោលនយោបាយភូមិឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ សកម្មភាពដែលរំពឹងថានឹងមាន រួមមាន ការកាត់បន្ថយកត្តាហានិភ័យនានា ដែលមានទំនាក់ទំនងជាមួយនឹងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ដូចជា ការប្រើប្រាស់ជាតិស្រវឹង ជាដើម។ មានការរំពឹងថា នឹងមានការកែលំអការសម្របសម្រួល និងការផ្តល់ឯកសារគាំទ្រនានា ដើម្បីបង្កើនការយល់ដឹង និងការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាឃុំចំពោះបរិយាប័ន្នសង្គម។ កម្មវិធី ACCESS នឹងធ្វើការងារជាមួយក្រសួង/មន្ទីរកិច្ចការនារី ក្រសួង/មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **ដើម្បីស្វែងយល់ និងមានឥទ្ធិពលលើការរៀបចំផែនការ ថវិកា និងការចុះអភិបាល នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ដែលលើកកម្ពស់បរិយាប័ន្នសង្គម ជាពិសេស សម្រាប់ជនពិការ និងពិចារណាពីការឆ្លើយតបសមស្របចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។** នេះតម្រូវឲ្យមានការចូលរួមសហការជាមួយក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (គ.ជ.អ.ប) ដែលជាតួអង្គសំខាន់ៗចំនួនពីរ សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

## អភិក្រមអនុវត្តសកម្មភាព និងភាពជាដៃគូសំខាន់ៗ ដែលស្នើឡើង

### កម្មវិធី ACCESS នឹងផ្តល់ថវិកាដល់ការផ្តល់សេវាដែលត្រូវបានរកឃើញថានៅខ្វះនៅឡើយ និងផ្តល់ជំនួយបច្ចេកទេស "អម" នឹងសកម្មភាពនេះ។

កម្មវិធី ACCESS នឹងប្រើប្រាស់អភិក្រមអម (ជាដំណើរការនៃការផ្តល់ជំនួយបច្ចេកទេសបែបជឿនលឿន និងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព) ដូចខាងក្រោម៖

- គាំទ្រដល់ដំណើរការនៃការរៀបចំផែនការ ក្នុងក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលផ្តល់អាទិភាពដល់ការទទួលខុសត្រូវក្នុងការផ្តល់សេវារបស់រាជរដ្ឋាភិបាលកម្ពុជា។
- ការជ្រើសរើសទីតាំងអនុវត្តសកម្មភាព នឹងផ្តោតលើកិច្ចព្រមព្រៀងរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ដោយពិចារណាលើលក្ខណៈវិនិច្ឆ័យជ្រើសរើសទីតាំង ដែលត្រូវបានរៀបចំរួមគ្នា។
- នៅថ្នាក់ជាតិ កម្មវិធី ACCESS នឹងពង្រឹងសមត្ថភាពពាក់ព័ន្ធនឹងដំណើរការថវិការបស់ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងគោលបំណងធានាឲ្យមានការផ្តល់ថវិកាបន្ថែម និងសមត្ថភាពអនុវត្តថវិកា និង
- កម្មវិធី ACCESS ក៏នឹងធ្វើការងារជាមួយតួអង្គពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ដើម្បីកែលំអការផ្តល់សេវាប្រកបដោយគុណភាព ជាពិសេស តាមរយៈការបង្កើនការយល់ដឹង និងការសម្របសម្រួលសេវានានា។

កម្មវិធីនេះនឹងបង្កើត**យន្តការវិនិយោគប្រកបដោយភាពប្រកួតប្រជែង (CIM)** ដើម្បីផ្តល់មូលនិធិដល់សកម្មភាពរយៈពេលវែង ដោយបែងចែកជាពីរជុំ ក្នុងរយៈពេលទាំងមូលនៃកម្មវិធីនេះ (ឆ្នាំទី ១ និងទី ៣)។ គណៈកម្មការ CIM របស់ កម្មវិធី ACCESS នឹងពិនិត្យលើសំណើទាំងនេះ និងធ្វើការសម្រេចចិត្តអំពីការវិនិយោគ។ សមាជិករបស់ CIMP រួមមាន៖ លេខាទីមួយរបស់ DFAT (ប្រធាន) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមហ៊ុនដែលជួលឲ្យគ្រប់គ្រងការងារនេះ និងសមាជិកឯករាជ្យម្នាក់ (អង្គការជនពិការ អង្គការមិនមែនរដ្ឋាភិបាល/វិស័យឯកជន)។ យន្តការ CIM នឹងផ្តល់ថវិកាដល់សកម្មភាពមួយចំនួន និងលើផែនការផ្តល់ជំនួយបច្ចេកទេសឯកទេស ដែលរៀបចំរួមគ្នាជាមួយនឹងក្រសួងគោលដៅនីមួយៗ។ យន្តការ CIM មានគោលបំណងបំពេញបន្ថែមលើថវិការបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រើប្រាស់សម្រាប់ផ្តល់ថវិកាដល់ជំនួយបច្ចេកទេស និងសកម្មភាពនានា (អនុវត្តដោយអ្នកអនុវត្តសកម្មភាព) ដើម្បីបំពេញចំណុចខ្វះខាតរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការផ្តល់សេវាដល់ជនពិការ និងស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។ យើងរំពឹងថា ដំណើរការខាងក្រោមនឹងត្រូវអនុវត្ត សម្រាប់យន្តការ CIM នេះ។

- ការរៀបចំផែនការរួមគ្នា នឹងត្រូវធ្វើឡើងក្នុងកិច្ចប្រជុំសម្រាប់សមាសភាគការងារ ដោយនឹងមានការកំណត់ និងឯកភាពគ្នាលើតម្រូវការ ដែលកម្មវិធី ACCESS អាចជួយបំពេញបាន តាមរយៈការផ្តល់ថវិកាដល់សកម្មភាពនានា។
- កម្មវិធី ACCESS នឹងចេញសេចក្តីអំពាវនាវឲ្យមានការដាក់សំណើបង្ហាញពីចំណាប់អារម្មណ៍ ជាការឆ្លើយតបចំពោះតម្រូវការដែលបានកំណត់ និងឯកភាពគ្នា។
- ក្រុមហ៊ុនដែលជួលឲ្យគ្រប់គ្រងការងារនេះ (ឬគណៈកម្មាធិការតូចណាមួយ ដែលទទួលបានប្រតិភូកម្មតាមរយៈកិច្ចប្រជុំរបស់សមាសភាគការងារនេះ) នឹងធ្វើការវាយតម្លៃលើការដាក់សំណើបង្ហាញពីចំណាប់អារម្មណ៍ ហើយបង្ហាញទៅកាន់កិច្ចប្រជុំពេញអង្គរបស់សមាសភាគការងារនេះ ដែលត្រូវកំណត់រកសំណើទាំងឡាយ ដែលអង្គប្រជុំរបស់សមាសភាគការងារនេះ ចង់ឃើញអនុវត្តទៅមុខទៀត។
- កម្មវិធី ACCESS នឹងអញ្ជើញអ្នកដាក់សំណើមួយចំនួន ឲ្យដាក់សំណើលំអិត។ បុគ្គលិកផ្តល់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងពិការភាព របស់កម្មវិធី ACCESS នឹងអាចជួយដល់អ្នកដាក់សំណើមួយចំនួន ធ្វើការកែសម្រួលសំណើរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាពនៃដំណើរការ CIM នេះ ឲ្យដល់កម្រិតអតិបរមា។
- គេរំពឹងថាអ្នកដាក់សំណើរួមមាន អង្គការមិនមែនរដ្ឋាភិបាល ទីភ្នាក់ងារសហប្រជាជាតិ ស្ថាប័នវិស័យឯកជន។
- កិច្ចប្រជុំរបស់សមាសភាគការងារនេះ នឹងផ្តល់អនុសាសន៍ដល់ CIMP អំពីសំណើដែលត្រូវបានជ្រើសរើស។
- CIMP ធ្វើការសម្រេចចិត្តអំពីសំណើ។
- សកម្មភាពត្រូវបានអនុវត្ត និងពិនិត្យតាមដាន។

ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា (ក្រសួងគោលដៅ អាជ្ញាធរថ្នាក់ក្រោមជាតិ) ដែលមានបំណងចង់ទទួលបានថវិកាគាំទ្រសកម្មភាពរបស់ខ្លួន តាមរយៈ CIM ចាំពាច់ត្រូវចុះកិច្ចព្រមព្រៀងជាមួយអ្នកលើកសំណើ (ដូចជា សំណើរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រជាជាតិ ជាដើម)។ សំណើទាំងនេះចាំបាច់ត្រូវបញ្ចូលកិច្ចព្រមព្រៀងលាយល័ក្ខណ៍អក្សរពីស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ថានឹងខិតខំបង្កើនថវិកាសម្រាប់ការផ្តល់សេវាទាំងនេះ នៅក្នុងឆ្នាំក្រោយៗទៀត។ សំណើប្រភេទនេះនឹងចូលរួមផ្តល់ថវិកាដល់សកម្មភាពនានា ដែលអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងករណីដែលថវិកាពីរាជរដ្ឋាភិបាលកម្ពុជាមានមិនគ្រប់គ្រាន់ ដូចជា ការរៀបចំសិក្ខាសាលា ឬការពិនិត្យឡើងវិញពាក់កណ្តាលអណត្តិ ។ល។

កម្មវិធី ACCESS នឹងមិនផ្តល់ថវិកាគាំទ្រដោយផ្ទាល់ដល់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការអនុវត្តសកម្មភាពនានាឡើយ ហើយថវិការបស់កម្មវិធី ACCESS ក៏មិនត្រូវប្រើប្រាស់ ដើម្បីផ្តល់ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ឬការទូទាត់ផ្សេងទៀត សម្រាប់ការចូលរួមក្នុងកម្មវិធី ឬសកម្មភាពនានារបស់កម្មវិធីនេះដែរ។ កម្មវិធី ACCESS ទទួលស្គាល់ថា ប្រភពថវិកាសមស្របសម្រាប់ក្រសួងគោលដៅ និងអាជ្ញាធរថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា គឺថវិការបស់រាជរដ្ឋាភិបាលកម្ពុជា។ សកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលធ្វើឡើងដោយកម្មវិធី ACCESS នឹងព្យាយាមគាំទ្រដល់ការបង្កើនថវិការបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ឆ្នាំទី ២-៥ (នឹងមានការបង្កើនថវិកា)។

ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ នឹងដើរតួនាទីជាទីភ្នាក់ងារបច្ចេកទេសនៅក្នុងកម្មវិធី ACCESS ដោយសារគាត់មានតួនាទីភារកិច្ចដឹកនាំកម្មវិធី និងគោលនយោបាយទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងពិការភាព ។ នៅក្នុងតួនាទីភារកិច្ចនេះ គាត់នឹងដើរតួនាទីសំខាន់ក្នុងការដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នអ្នកផ្តល់សេវាដ៏ទៃទៀតដូចជា ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងដឹកនាំផ្នែកកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងគាំទ្រដល់ការបង្កើនសមត្ថភាពរបស់ក្រសួងពាក់ព័ន្ធក្នុងការគ្រប់គ្រងថវិការ។ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងមានតួនាទីក្នុងការដឹកនាំគ្រប់គ្រង CIM ។ ក្រសួងទាំងអស់ (រួមទាំងក្រសួងពាក់ព័ន្ធបន្ទាប់បន្សំដ៏ទៃទៀត) នឹងអាចទទួលបានការគាំទ្រជំនួយបច្ចេកទេស ដើម្បីគាំទ្រដល់ការបំពេញភារកិច្ចទាំងនេះ ។

## អភិបាលកិច្ចកម្មវិធី

គណៈកម្មាធិការដឹកនាំអន្តរក្រសួងដែលមានសមាសភាពពីរាជរដ្ឋាភិបាលកម្ពុជា-រដ្ឋាភិបាលអូស្ត្រាលី ដែលត្រូវជួបប្រជុំឡើងរៀងរាល់ ៦ ខែម្តង ត្រូវបានលើកស្នើជាគណៈកម្មាធិការដឹកនាំរបស់កម្មវិធី ACCESS ដែលនឹងផ្តល់ការណែនាំជាយុទ្ធសាស្ត្រ និងពិនិត្យឡើងវិញលើវឌ្ឍនភាពនានា។ គេរំពឹងថា តំណាងក្នុងគណៈកម្មាធិការនេះ នឹងមានសមាសភាពពីក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (កុងស៊ុលទទួលបន្ទុកការងារអភិវឌ្ឍន៍ ឬការងារស្រដៀងគ្នា) និងប្រធានក្រុមរបស់កម្មវិធី ACCESS។ ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏អាចត្រូវបានអញ្ជើញឲ្យចូលរួម តាមការឯកភាពគ្នា (ដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាដើម)។ គណៈគ្រប់គ្រង និងបុគ្គលិកផ្តល់ជំនួយបច្ចេកទេសរបស់កម្មវិធីនេះ អាចត្រូវបានអញ្ជើញឲ្យចូលរួម ជាអ្នកផ្តល់ប្រឹក្សា។ DFAT និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវឯកភាពគ្នាលើការរៀបចំសមស្រប សម្រាប់គណៈកម្មាធិការដឹកនាំកម្មវិធី ACCESS នេះ។

## ការទទួលបានថវិកា តាមរយៈយន្តការ CIM និងការពិនិត្យតាមដានវឌ្ឍនភាព

កិច្ចប្រជុំសម្រាប់សមាសភាគការងារតាមវិស័យ ក្នុងក្រសួងគោលដៅនីមួយៗ នឹងធ្វើការរៀបចំផែនការរួមគ្នា និងរៀបចំនូវសំណើសកម្មភាព សម្រាប់គាំទ្រដល់កិច្ចពិគ្រោះយោបល់កម្រិតគោលនយោបាយ។ ក្រសួងគោលដៅនីមួយៗត្រូវធ្វើជាប្រធានកិច្ចប្រជុំទាំងនេះ ដោយត្រូវមានតំណាងចូលរួមរហូតដល់ ៣ នាក់។ ការចូលរួមរបស់ក្រសួងគោលដៅ ត្រូវបានសន្មត់ថាជាការរួមបដិភាគមិនមែនថវិការបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះកម្មវិធីនេះ។ ដំណើរការកិច្ចប្រជុំរួមគ្នាទាំងនេះ នឹងផ្តល់លទ្ធភាពឲ្យតួអង្គពាក់ព័ន្ធនានាធ្វើការងាររួមគ្នា ដើម្បីរៀបចំសកម្មភាព ដែលឆ្លើយតបទៅនឹងអាទិភាពនានា (ឧ. ក្រសួងកិច្ចការនារីបង្ហាញពីបំណងចង់ពង្រីកអភិក្រមមជ្ឈមណ្ឌលផ្តល់សេវាគ្រប់បែបយ៉ាងដល់ជនរងគ្រោះ និងគាំទ្រដល់ការបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានបំណងចង់ពង្រឹងការផ្តោតការយកចិត្តទុកដាក់លើការអប់រំ និងការបណ្តុះបណ្តាល់វិជ្ជាជីវៈ ដល់ជនពិការ)។ កិច្ចប្រជុំនៃសមាសភាគការងារនេះ ក៏អាចផ្តល់ឱកាសឲ្យមានការបង្កើនការធ្វើសុខុដុមនីយកម្មអ្នកផ្តល់ជំនួយ ដែលគាំទ្រដល់ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពផងដែរ។ មានការស្នើឲ្យមានការផ្តល់ថវិកាចំនួន ២ ជុំ៖ ឆ្នាំទី ១ (សម្រាប់ឆ្នាំទី ១-៣) និងឆ្នាំទី ៣ (សម្រាប់ឆ្នាំទី ៤ និងទី ៥)។ អ្នកអនុវត្តសកម្មភាព រួមមាន អង្គការជនពិការ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងវិស័យឯកជន។[10] DFAT នឹងប្រើប្រាស់ការរៀបចំកិច្ចសន្យាជាក់លាក់ សម្រាប់ទីភ្នាក់ងារសហប្រជាជាតិ ស្របតាមដំណើរការធ្វើសេចក្តីសម្រេចចិត្តនេះ។

## ការគ្រប់គ្រងការអនុវត្ត

ក្រុមហ៊ុនគ្រប់គ្រងដែលជួលដោយ DFAT គឺជាអ្នកអនុវត្តកម្មវិធី ACCESS នេះ។ ក្រុមការងាររតាក់តែងកម្មវិធី បានធ្វើការពិចារណាលើទម្រង់នៃការអនុវត្តជាជ្រើសផ្សេងទៀត (ដូចជា SWAp ការផ្តល់ថវិកាដោយផ្ទាល់ ការផ្តល់ថវិកាដល់ទីភ្នាក់ងារសហប្រជាជាតិ ឬអង្គការអន្តរជាតិឲ្យអនុវត្តកម្មវិធីនេះ) និងបានរកឃើញថា ដោយសារបទពិសោធន៍វិនិយោគកន្លងមករបស់ DFAT ក្នុងកម្មវិធីស្រដៀងគ្នានេះ ក្នុងប្រទេសកម្ពុជា ប្រសិទ្ធភាពនៃការគ្រប់គ្រង ភាពឆ្លើយតប និងការបានផលពីប្រាក់ដែលបានចំណាយ នឹងអាចបង្កើនបានជាអតិបរមា តាមរយៈការប្រើប្រាស់ទម្រង់ជួលក្រុមហ៊ុនឲ្យគ្រប់គ្រងការងារនេះ (Managing Contractor model)។ មុខងារ ដែលរំពឹងថានឹងមាន រួមមាន៖ ការធ្វើលទ្ធកម្ម និងការគ្រប់គ្រងបុគ្គលិកផ្តល់ជំនួយបច្ចេកទេសជាតិ និងអន្តរជាតិ ដែលមានបទពិសោធន៍ខាងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងពិការភាព ការពិនិត្យតាមដាន និងវាយតម្លៃ - នេះអាចមានជាការជួលអង្គការជនពិការឲ្យផ្តល់សេវាជាក់លាក់នានា ដូចជា សវនកម្មពិការភាព ការ

[10] ការវិភាជន៍ថវិកាដល់វិស័យឯកជន ត្រូវធ្វើក្នុងទម្រង់ជាកិច្ចសន្យា មិនមែនជាការផ្តល់ជំនួយនោះទេ។

របាយការណ៍ពីការបំពេញការងារនិងលទ្ធផលសម្រេចបាន និងការពិនិត្យតាមដាននិងការគ្រប់គ្រងការវិនិយោគ ជាដើម។

## ការពិនិត្យតាមដាន ការវាយតម្លៃ និងការរៀនសូត្រ

សកម្មភាពរបស់កម្មវិធីនេះនឹងផលិតនូវទិន្នន័យពាក់ព័ន្ធ ដើម្បីឲ្យដំណើរការថវិកាកាន់តែមានភាពល្អប្រសើរជាងមុន និងបង្កើនថវិកា [11] និងល្អបំផុតកិច្ចខិតខំប្រឹងប្រែងពង្រឹងគណនេយ្យភាពសង្គម។ សូចនាកររួមសម្រាប់ស្ថាប័នទទួលជំនួយ ដែលធ្វើការងារពាក់ព័ន្ធនឹងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព **នឹងត្រូវបញ្ចូលទៅក្នុងអភិក្រមពិនិត្យតាមដាន វាយតម្លៃ និងរៀនសូត្រ (MEL) នេះ។** ស្ថាប័នទទួលជំនួយត្រូវប្រើប្រាស់ប្រព័ន្ធរបស់ខ្លួន ដើម្បីផលិតទិន្នន័យ។ អ្នកជំនាញ MEL របស់កម្មវិធី ACCESS ក៏នឹងផ្តល់ការគាំទ្រដល់ការរៀបចំឯកសារអប់រំផ្សព្វផ្សាយគំរូ សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពមិត្តអប់រំមិត្ត និងអាចយកទៅប្រើប្រាស់ សម្រាប់សកម្មភាពដែលមានសក្តានុពលផ្សេង ទៀត។ នៅពេលធ្វើសកម្មភាពនៅកម្រិតសហគមន៍[12] ស្ថាប័នដែលទទួលបានជំនួយត្រូវប្រមូលទិន្នន័យអំពីករណីអំពើហិង្សា និងការបញ្ជូនជនរងគ្រោះទៅរកសេវា ក៏ដូចជាទិន្នន័យបែងចែកលំអិតអំពីការប្រើប្រាស់ និងការបញ្ជូនទៅរកសេវាសម្រាប់ជនពិការ។ ទិន្នន័យទាំងនេះនឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្មវិធី ACCESS ដែលផ្តោតលើចំណុចប្រសព្វគ្នារវាងវិស័យទាំងពីរនេះ។ កម្មវិធី ACCESS នឹងរៀបចំ**ដំណើរការឆ្លុះបញ្ចាំងរួមគ្នាជាប្រចាំឆ្នាំ ផ្សារភ្ជាប់ជាមួយនឹងផែនការប្រចាំឆ្នាំ។** នៅចុងឆ្នាំទី ៣ ការបូកសរុបការវិនិយោគដែលធ្វើឡើងដោយកម្មវិធី ACCESS នឹងគាំទ្រដល់ការវិនិយោគជុំចុងក្រោយដែលមានទំហំតូចជាងជុំមុនៗ នៅឆ្នាំទី ៣ (សម្រាប់ឆ្នាំទី ៤ និងទី ៥)។ ការពិនិត្យឡើងវិញពាក់កណ្តាលអណត្តិដោយឯករាជ្យ នឹងធ្វើឡើងក្នុងឆ្នាំទី ៣។ កម្មវិធី ACCESS នឹងរៀបចំ**របាយការណ៍វឌ្ឍនភាព និងរបាយការណ៍ហិរញ្ញវត្ថុរៀងរាល់ ៦ ខែម្តង** ក៏ដូចជារបាយការណ៍លទ្ធផលសកម្មភាព ដូចដែលតម្រូវដោយរាជរដ្ឋាភិបាលកម្ពុជា និង DFAT។ ក្នុងករណីដែលអាចធ្វើបាន របាយការណ៍វឌ្ឍនភាពដែលពុំមានព័ត៌មានហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាព នឹងត្រូវផ្តល់ដល់អ្នកពាក់ព័ន្ធនឹងកម្មវិធី ACCESS ផងដែរ។

## ហានិភ័យ និងបញ្ហាប្រឈមសំខាន់ៗ ដែលធ្វើឲ្យរាំងស្ទះដល់ការសម្រេចជោគជ័យ

- **តម្រូវការសមត្ថភាព និងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស** ការកសាងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ និងសមត្ថភាពផ្តល់សេវាក្នុងពេលទន្ទឹមគ្នា អាចជាការដាក់បន្ទុកលើក្រសួងពាក់ព័ន្ធ។ កម្មវិធី ACCESS ចាំបាច់ត្រូវកំណត់ចំណុចដៅសម្រាប់ការអនុវត្តដែលមានលក្ខណៈប្រាកដនិយម បែងចែកតួនាទីនិងការទទួលខុសត្រូវឲ្យបានច្បាស់លាស់ ទាញប្រយោជន៍ពីឱកាសនានា កសាងប្រព័ន្ធ MEL ផ្ទៃក្នុង និងធ្វើ

[11] ដូចជា ទិន្នន័យអំពីករណីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងទិន្នន័យអំពីការប្រើប្រាស់សេវា ជាដើម។

[12] មានការទទួលស្គាល់ថា សកម្មភាពនេះត្រូវធ្វើដោយមានការយកចិត្តទុកដាក់បំផុត។ ប៉ុន្តែ បទពិសោធន៍នៃកម្មវិធី TAF ក្រោមកម្មវិធី EVAW ដែលទទួលបានការគាំទ្រពី DFAT កន្លងមក បង្ហាញថា គេអាចប្រមូលទិន្នន័យនេះបាននៅថ្នាក់សហគមន៍។

ការងារជាមួយនឹងតួអង្គពាក់ព័ន្ធនានា (ដូចជាក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាល់វិជ្ជាជីវៈ)

› **ការប្រើប្រាស់អភិក្រមដែលមានលក្ខណៈបែកខ្ញែកពីគ្នា អាចធ្វើឲ្យខាតបង់ការវិនិយោគ៖** ប្រវត្តិនៃការអនុវត្តកម្មវិធីដាច់ដោយឡែកៗពីគ្នាកន្លងមក អាចធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃកម្មវិធី ACCESS និងភាពប្រសព្វគ្នានៃសមាសភាគនានា។ គេរំពឹងថា ការពិនិត្យលើសំណើគម្រោង និងការផ្តល់ការគាំទ្រក្នុងទម្រង់ជាជំនួយបច្ចេកទេសដល់ក្រសួងគោលដៅ និងអង្គការមិនមែនរដ្ឋាភិបាល នឹងអាចកាត់បន្ថយហានិភ័យនេះឲ្យនៅទាបជាអប្បបរមា។

› **ការវិភាជន៍ថវិការបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់សេវាពាក់ព័ន្ធនឹងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងពិការភាព ពុំបានកើនឡើងឡើយ៖** ការបង្កើនការវិភាជន៍ថវិការបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការផ្តល់សេវាទាំងនេះ មិនអាចកើតឡើងបានឡើយ។ កម្មវិធី ACCESS នឹងផ្តល់ជំនួយបច្ចេកទេសផ្នែកការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បន្តធ្វើការវិភាគពីស្ថានភាពនយោបាយនិងសេដ្ឋកិច្ច ដាក់ឲ្យ អនុវត្តនូវអភិក្រមរៀបចំថវិកាឆ្លើយតបចំពោះយេនឌ័រ និងកសាងទំនាក់ទំនងក្នុងវិស័យទាំងនេះ និងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យនេះ។

› **ដំណើរការបោះឆ្នោតនាពេលខាងមុខអាចពន្យាពេលការអនុវត្តគម្រោង ៖** ការបោះឆ្នោតសកល ដែលគ្រោងនឹងធ្វើឡើងក្នុងឆ្នាំ ២០១៨ អាចពន្យាពេលក្នុងការចាប់ផ្តើមអនុវត្តគម្រោង ដោយអាស្រ័យទៅលើការផ្លាស់ប្តូរតួនាទីខ្លះនៃក្រសួងសំខាន់ៗ។

## ក្របខ័ណ្ឌពេលវេលាសម្រាប់ការចូលរួមអនុវត្តសកម្មភាព និងធនធានដែលត្រូវបានសន្យា

**ថវិកាប្រមាណជា ២៥ លានដុល្លារអូស្ត្រាលី (ប្រមាណជា ២០ លានដុល្លារអាមេរិច) សម្រាប់រយៈពេល ៥ ឆ្នាំ** ត្រូវបានស្នើឡើង សម្រាប់រយៈពេលរបស់កម្មវិធីនេះ ចាប់ពីពាក់កណ្តាលឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣។ ៥០ ភាគរយ នៃថវិកានេះ (ស្មើនឹង ១២,៥ ដុល្លារអូស្ត្រាលី/ ១០ លានដុល្លារអាមេរិច) នឹងមានសម្រាប់ចំណាយលើសកម្មភាព ហើយថវិកាដែលនៅសល់ត្រូវបែងចែករវាងការចំណាយលើការគ្រប់គ្រង (ដូចជា បុគ្គលិកផ្តល់សេវារបស់ក្រុមហ៊ុន) និងបុគ្គលិកផ្តល់ជំនួយបច្ចេកទេសតាមឯកទេស (ប្រធានក្រុម ទីប្រឹក្សាផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រធានក្រុមខាងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងពិការភាព និងបុគ្គលិកខាងពិនិត្យតាមដាន និងវាយតម្លៃ) - ដោយប្រភេទនីមួយៗមានថវិកា ៦,២៥ លានដុល្លារអូស្ត្រាលី (៥ លានដុល្លារអាមេរិច)។ អ្នកដេញ

ថ្លៃត្រូវបានលើកទឹកចិត្តឲ្យបង្ហាញពីគំនិតថ្មីៗសម្រាប់សន្សំសំចៃចំណាយ ក្នុងឯកសារដេញថ្លៃរបស់ខ្លួន។ តួលេខខាងក្រោម គ្រាន់តែជាតួលេខបណ្តោះអាសន្នតែប៉ុណ្ណោះ។

| *ពិពណ៌នា* | *គិតជាលាន ប្រចាំឆ្នាំ* | *គិតជាលាន សម្រាប់ រយៈពេល ៥ ឆ្នាំ* |
|---|---|---|
| ថវិកាសរុបដែលមាន សម្រាប់សកម្មភាព | AUD 2.5 / USD 2.0 | AUD 12.5 /USD 10.0 |
| ចំណាយលើការគ្រប់គ្រង (រាប់បញ្ចូល សេវារបស់ក្រុមហ៊ុនដែលផ្តល់ឲ្យគ្រប់គ្រង មិនរាប់បញ្ចូលជំនួយបច្ចេកទេស) | AUD 1.25 / USD 1.0 | AUD 6.25 /USD 5.0 |
| ចំណាយលើបុគ្គលិកផ្តល់ជំនួយបច្ចេកទេសតាមឯកទេស | AUD 1.25 / USD 1.0 | AUD 6.25 / USD 5.0 |
| ចំណាយសរុបរបស់កម្មវិធី | | AUD 25.00 / USD 20.0 |

ថវិកានេះនឹងផ្តល់បុគ្គលិកជំនួយបច្ចេកទេសតាមឯកទេស ដើម្បីធ្វើការងារជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណង៖

- ពង្រឹងដំណើរការថវិកា និងនិរន្តរភាពហិរញ្ញវត្ថុនៃការផ្តល់សេវាប្រកបដោយគុណភាព ក្នុងវិស័យអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងពិការភាព។
- ពង្រឹងទំនាក់ទំនងនៃការផ្តល់សេវារវាងរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល ទីភ្នាក់ងារពហុភាគី និងវិស័យឯកជន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ពង្រឹងបរិយាប័ន្នសេដ្ឋកិច្ច សម្រាប់ជនពិការ រាប់បញ្ចូលទាំងស្ត្រីរងផលប៉ះពាល់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រផង តាមរយៈការបង្កើតទំនាក់ទំនងឲ្យកាន់តែរឹងមាំរវាងសេវាស្តារលទ្ធភាពពលកម្ម និងបរិយាប័ន្នសេដ្ឋកិច្ច។
- ពង្រឹងប្រសិទ្ធភាពមុខងាររបស់ក្រសួងគោលដៅ (ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) និងតួនាទីរបស់ក្រសួងទាំងពីរ ក្នុងនាមជាប្រភពផ្តល់ជំនួយបច្ចេកទេស គោលនយោបាយ និងសម្របសម្រួលក្រសួងពាក់ព័ន្ធនឹងថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។

- ជម្រុញឲ្យមានការផ្តល់សេវាប្រកបដោយគុណភាព ដើម្បីគាំទ្រដល់ស្ត្រីពិការដែលទទួលរងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងស្ត្រីផ្សេងទៀត ដែលមានជំងឺចិត្តសង្គម ដោយសារអំពើហិង្សា និង
- អនុញ្ញាតឲ្យអូស្ត្រាលីបន្តការរួមចំណែកខ្ពស់ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងវិស័យទាំងពីរ។

តារាងបង្ហាញព័ត៌មានលំអិតបន្ថែមទៀត មានក្នុង**ឧបសម្ព័ន្ធទី ១២**។

ដោយហេតុថាកម្មវិធី ACCESS មានមូលដ្ឋានផ្អែកលើការវិនិយោគដែល DFAT មានកន្លងមកក្នុងប្រទេសកម្ពុជា និងសហការជាមួយតួអង្គពាក់ព័ន្ធក្នុង និងក្រៅរដ្ឋាភិបាលបច្ចុប្បន្នភាគច្រើន ការវិនិយោគនេះត្រូវបានចាត់ទុកថា មាន**ហានិភ័យទាប**។

តារាងដែលបង្ហាញដោយសង្ខេបពីភាពខុសប្លែកគ្នាសំខាន់ៗនៃអភិក្រមដែលប្រើប្រាស់ក្នុងកម្មវិធីមុន (កម្មវិធី DRIC និង EVAW) និងកម្មវិធី ACCESS មានក្នុង**ឧបសម្ព័ន្ធទី ១០**។